ព្រឹត្តិបត្រ

# នារីរតនៈ

Neary Rattanak Newsletter

២០១៤. លេខ៥០ ឆ្នាំទី៨

# វេទិកា យុវជន រួមគ្នាទប់ស្កាត់ អំពើហិង្សាលើស្ត្រី



វេទិកានៅវិទ្យាល័យហ្វាពន្លឺសិល្បៈ ខេត្តបាត់ដំបង



វេទិកានៅមហាវិទ្យាល័យបៀលប្រាយ ខេត្តសៀមរាប



វេទិកានៅវិទ្យាល័យខេត្តកោះកុង



វេទិកានៅវិទ្យាល័យហ៊ុនសែន វាលវិញ



វេទិកានៅវិទ្យាល័យក្រុងព្រះសីហនុ

ចេញផ្សាយពីនាយកដ្ឋានព័ត៌មាន នៃក្រសួងកិច្ចការនារី
Organized by Information Department of Ministry of Women's Affairs
គេហទំព័រ: www.mwa.gov.kh

## គណៈកម្មការត្រួតពិនិត្យ

-លោកជំទាវ ខេង សំវាដា រដ្ឋលេខាធិការ

-លោកជំទាវ ឡុង សុផល្លី អនុរដ្ឋលេខាធិការ

-លោកស្រី ឌី វ៉ានី ប្រធាននាយកដ្ឋាន

-លោកស្រី យិន សារ៉ាត់ អនុប្រធាននាយកដ្ឋាន

## គណៈកម្មការនិពន្ធ

-លោក ប៉ែន ជា

-លោកស្រី កែវ វឌ្ឍនា

-លោកស្រី កែវ វណ្ណនី

-លោកស្រី តែ សុខខេង

## រៀបរៀង និងត្រាហ្វិចកុំព្យូទ័រ

-លោកស្រី ប្រាក់ សោភា

-លោក ផុន ពុធបូរី


# មាតិកា


- ពិធីប្រកាសផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវស្តីពីអំពើហិង្សា..០១
- ពិធីផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវឯកសារ...................០២
-សិក្ខាសាលាប្រចាំឆ្នាំស្តីពី ការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ.០៣
-សកម្មភាពអន្តរជាតិសំខាន់ៗរបស់ថ្នាក់ដឹកនាំ.............................០៤
-សិស្សឆ្នើមនិទ្ទេស A ឆ្នាំ២០១៤...................................................០៦
-សិក្ខាសាលាថ្នាក់ជាតិ ស្តីពី ការអនុវត្តផែនការសកម្មភាព............០៩
-ណែនាំពីតួនាទីភារកិច្ចដល់គណៈកម្មការចម្រុះថ្នាក់ក្រោមជាតិ....១០
-សកម្មភាពទប់ស្កាត់អំពើហិង្សាលើស្ត្រី.........................................១១
-ឥទ្ធិពលនៃការផ្លាស់ប្តូរ.......................................................................១២
-វេទិកា យុវជនរួមគ្នាលប់បំបាត់អំពើហិង្សាលើស្ត្រី.........................១៣
-វគ្គបណ្តុះបណ្តាល ទប់ស្កាត់អំពើជួញដូរមនុស្ស..........................១៤
-សកម្មភាពលើកកម្ពស់សុខភាពស្ត្រី..............................................១៥
-វេទិកា ស្តីពី បញ្ហាប្រឈមនៅក្នុងសង្គម.......................................១៦
-ការងារដើម្បីពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី...............១៧
-ការកសាងសមត្ថភាព........................................................................១៨
-.គម្រោងផែនការថវិកា ឆ្លើយតបនឹងយេនឌ័រ................................១៩
-វគ្គបណ្តុះបណ្តាលស្តីពី ការបញ្ជ្រាបយេនឌ័រ.................................២០
-វគ្គបណ្តុះបណ្តាលស្វែរកការគាំទ្រមតិ.............................................២១
-ផ្តល់ភាពអង់អាចដល់ស្ត្រី និងក្មេងស្រីពិការ.................................២២
-ជីវិតស្ត្រីលក់ក្តាម.............................................................................២៣
-ការតស៊ូនាំមកនូវភាពជោគជ័យ.......................................................២៤



**ការិយាល័យនិពន្ធ**
**នាយកដ្ឋានព័ត៌មាន ក្រសួងកិច្ចការនារី ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំIII សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ**
Editorial Office : Information Department, Ministry of Women's Affairs
Street Trung Meann,Phum DamNakThom III, S.K. Steng MeanChey, Khan MeanChey, Phnom Penh, Cambodia. Tel: 023 880 737

# ពិធីប្រកាសផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវ ស្តីពី អំពើហិង្សាលើកុមារ




លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចូលរួមប្រកាសផ្សព្វផ្សាយលទ្ធផល នៃការសិក្សាស្រាវជ្រាវ ស្តីពីអំពើហិង្សាលើកុមារ កាលពីថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៤ នៅសណ្ឋាគារ Sofitel Phokeethra រាជធានីភ្នំពេញ។

ការសិក្សានេះដឹកនាំដោយក្រសួងកិច្ចការនារី



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ រួមសហការជាមួយក្រសួងស្ថាប័នពាក់ពន្ធ័ និងដៃគូអភិវឌ្ឍន៍ បានធ្វើការស្រាវជ្រាវលើជនវ័យក្មេងចាប់ពីអាយុ១៣-២៤ឆ្នាំ ចំនួន ២៣៧៦ នាក់ ក្នុងនោះស្រ្តីចំនួន ១,២៥៥នាក់ នៅទូទាំង២៥ខេត្ត-ក្រុង ។

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះជាធាតុចូលមួយរួមចំណែកកសាងផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើកុមារ ដែលនឹងត្រូវរៀបចំក្របខ័ណ្ឌនៃការបង្ការទប់ស្កាត់ ផ្តល់សេវាដែលមានប្រសិទ្ធភាពទាន់ពេលវេលាកិច្ចអន្តរាគមន៍នានា ដើម្បីធានាជួយដល់កុមាររងគ្រោះ និងផ្តន្ទាទោសជនល្មើសពាក់ពន្ធ័នឹងការប្រព្រឹត្តអំពើហិង្សា និងការរំលោភបំពានលើកុមារ ពិសេសការរំលោភបំពាន់ផ្លូវភេទលើកុមារី និងស្រ្តីវ័យក្មេង៕ *សារ៉ាត់*

# ពិធីផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវឯកសារ ស្តីពីការប៉ាន់ប្រមាណស្ថានភាពយេឌ័រនៅកម្ពុជា និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ (២០១៤-២០១៨)




លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាគណៈអធិបតីក្នុងពិធីផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវឯកសារស្តីពីការប៉ាន់ប្រមាណស្ថានភាពយេឌ័រនៅកម្ពុជាលើកទី៣ មានចំណងជើងថាៈ " ដំណើរឆ្ពោះទៅសម្រេចបានសមភាពយេនឌ័រ " និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ កាលពីថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៤ ។

ឯកសារនេះបានបង្ហាញពីទិដ្ឋភាពទូទៅអំពីព័ត៌មាន និងទិន្នន័យប្រកបដោយបច្ចុប្បន្នភាពពាក់ព័ន្ធនឹងស្ថានភាពយេនឌ័រលើគ្រប់វិស័យ និងមាន១០ជំពូកគឺ៖

១.ការបញ្ជ្រាបយេនឌ័រ៖ បរិបទស្ថាប័ន ភាពជាដៃគូ និងគោលនយោបាយ

២.ទំនាក់ទំនង និងឥរិយាបថយេនឌ័រ

៣.ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី

៤.យេនឌ័រក្នុងវិស័យអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ

៥.យេនឌ័រ និងសុខភាព

៦.យេនឌ័រ និងមេរោគអេដស៍

៧.អំពើហិង្សាលើស្ត្រី និងក្មេងស្រី

៨.ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយ

៩.ក្រុមស្ត្រី និងក្មេងស្រីដែលងាយរងគ្រោះ

១០.យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍន៍បៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ

ឯកសារនេះនឹងជួយដល់អ្នករៀបចំគោលនយោបាយ ផែនការកម្មវិធី ក្នុងការប្រើប្រាស់ព័ត៌មាន និងទិន្នន័យជាក់លាក់ដើម្បីរៀបចំគោលនយោបាយ ផែនការ និងកម្មវិធី នៅក្នុងវិស័យរបស់ខ្លួន ធ្វើឱ្យប្រសើរឡើងនូវសិទ្ធិ ឋានៈ តួនាទី និងជីវភាពរស់នៅរបស់ស្ត្រីកម្ពុជា៕

*សារ៉ាត់*

# សិក្ខាសាលាប្រចាំឆ្នាំ ស្តីពី ការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ




លោកជំទាវវេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ជាគណៈអធិបតីក្នុងសិក្ខាសាលាប្រចាំឆ្នាំ ស្តីពី ការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី ១៨-១៩ ខែធ្នូ ឆ្នាំ២០១៤ នៅសណ្ឋាគារតាវអែរផត រាជធានីភ្នំពេញ។




សិក្ខាសាលានេះមានគោលបំណងពិនិត្យលើវឌ្ឍនភាពនៃការបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនៅថ្នាក់ក្រោមជាតិ និងលើកទិសដៅសកម្មភាពការងារនៅឆ្នាំ២០១៥ ។ សមាសភាពចូលរួមមាន ថ្នាក់ដឹកនាំក្រសួងកិច្ចការនារី ថ្នាក់ដឹកនាំលេខាធិការដ្ឋានគណៈកម្មាធិការជាតិ សម្រាប់អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ប្រធាន អនុប្រធានមន្ទីរកិច្ចការនារី រាជធានី/ខេត្ត មន្ត្រីទទួលបន្ទុកការងារយេនឌ័រ និងក្រុមជំនួយការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ទាំង ២៥ រាជធានី/ខេត្ត សរុបចំនួន ១៥០ រូប ក្នុងនោះបុរស ១២ រូប។ *សារ៉ាត់*

# សកម្មភាពអន្តរជាតិសំខាន់ៗរបស់ថ្នាក់ដឹកនាំក្រសួងកិច្ចការនារី






លោកជំទាវវេជ្ជ. **អ៊ីង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានទទួលពានរង្វាន់ស្ត្រីដ៏ឆ្នើមបំផុតរបស់ APEC ឆ្នាំ២០១៤ ក្នុងវេទិកា " The APEC Women Leadership Forum 2014 " នាថ្ងៃទី២១-២២ ខែសីហា ឆ្នាំ២០១៤ នៅសាធារណរដ្ឋប្រជាមានិតចិន។




លោកជំទាវវេជ្ជ. **អ៊ីង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ថ្លែងសុន្ទរកថាក្នុងសិក្ខាសាលា " Asian Leaders Program" នៅសាធារណរដ្ឋកូរ៉េ នាថ្ងៃទី0១-0៤ ខែកញ្ញា ឆ្នាំ២០១៤



លោកជំទាវវេជ្ជ. **អ៊ីង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានអនុញ្ញាតឱ្យលោកស្រី **ជូ លីជុង** ដែលទទួលតំណែងថ្មីជាអនុប្រធានផ្នែកទទួលបន្ទុកបេសកកម្មប្រចាំនៅកម្ពុជា នៃស្ថានទូតអាមេរិក បានចូលជួបសម្តែងការគួរសម កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤ នៅក្រសួងកិច្ចការនារី។




ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងកិច្ចការនារី និង
អង្គការឃែរអន្តរជាតិនៅកម្ពុជា លើគម្រោងកន្លែងធ្វើការមានសុវត្ថិភាព និងសហគមន៍មានសុវត្ថិភាព
ក្រោមអធិបតីភាពលោកជំទាវវេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី
នៅសាលប្រជុំក្រសួងកិច្ចការនារី ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ២០១៤




លោកជំទាវវេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ជួបជាមួយអង្គការ OXFAM
ជាមួយគ្នានោះ អង្គការ OXFAM បានប្រគល់ឡានចំនួន ០១ គ្រឿង ដល់ក្រសួងកិច្ចការនារី
កាលពីថ្ងៃទី ១៩ ខែសីហា ឆ្នាំ ២០១៤ នៅ ក្រសួងកិច្ចការនារី ។




កាលពីថ្ងៃទី១៥ ដល់ ១៧ខែតុលា ឆ្នាំ២០១៤ លោកជំទាវ **ខេង សំ វ៉ាដា** រដ្ឋលេខាធិការក្រសួង
កិច្ចការនារី បានដឹកនាំគណៈប្រតិភូ នៃក្រសួងកិច្ចការនារី ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអាស៊ាន
ស្តីពី ស្ត្រីលើកទី១៣ និងកិច្ចប្រជុំគណៈកម្មាធិការអាស៊ានបូក៣ ស្តីពី ស្ត្រី លើកទី៦
នៅទីក្រុងយ៉ាងហ្គូន ប្រទេសភូមា ។

# សិស្សឆ្នើមនិទ្ទេស A នាសម័យប្រឡងមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៤

## ខេត្តព្រៃវែងៈ កញ្ញា យាន សោភា ចង់ធ្វើជាគ្រូពេទ្យ



អតីតសិស្សថ្នាក់ទី១២នៃវិទ្យាល័យព្រៃវែងព្រះអង្គឌួងកញ្ញា យាន សោភា បានផ្តល់ក្តីសង្ឃឹមចំពោះខ្លួនឯង និងគ្រួសារយ៉ាងត្រចះត្រចង់ ខណៈនាងទទួលលទ្ធផលនិទ្ទេសA ក្នុងចំណោមបេក្ខជនជិត ៩ម៉ឺននាក់ ឆ្នាំ២០១៤នេះដែលជាឆ្នាំរឹតបន្តឹង។ ជាការគួរឱ្យកោតសសើរនោះ កញ្ញា យាន សោភា ត្រូវបានសម្តេចតេជោ **ហ៊ុន សែន** យកចិត្តទុកដាក់ផ្តល់អាហារូបករណ៍រយៈពេល៨ឆ្នាំរហូតរៀនចប់បរិញ្ញាបត្រ។ ស្ថិតក្នុងវ័យ ១៨ឆ្នាំ សោភា មានស្រុកកំណើតនៅភូមិខ្នារ ឃុំព្រៃទឹង ស្រុក ស៊ីធរកណ្តាល ខេត្តព្រៃវែង។ ជាកូនទី២ក្នុងចំណោមបងប្អូនស្រីបីនាក់ ។ សោភា មានឪពុកជាគ្រូបង្រៀននៅជនបទ និងម្តាយជាកសិករ។ កញ្ញា យាន សោភា ជាសិស្សម្នាក់រៀនពូកែតាំងពីថ្នាក់បឋមរហូតដល់វិទ្យាល័យដែលភាគច្រើនទទួលបានលទ្ធផលល្អ។ បច្ចុប្បន្នកញ្ញា យាន សោភា កំពុងស្នាក់នៅជាមួយបងស្រីក្នុងរាជធានីភ្នំពេញ ដោយមានបំណងបន្តការសិក្សានៅសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។ សោភា បាននិយាយថាៈ ខ្ញុំនឹងតស៊ូព្យាយាមបោះជំហានចាប់យកនៅមុខជំនាញពេទ្យឱ្យបានជោគជ័យ ព្រោះខ្ញុំចង់ក្លាយជាអ្នកគ្រូពេទ្យដ៏ល្អម្នាក់ ដើម្បីរួមចំណែកជួយដល់សង្គម និងម្យ៉ាងដើម្បីតបស្នងសងគុណដល់ការផ្គត់ផ្គង់របស់ឪពុកម្តាយដែលតែងតែគាំទ្រ និងមានទំនុកចិត្តមកលើខ្ញុំ៕ ***ស្រីពេជ្រ***

## ខេត្តកំពង់ស្ពឺៈ កញ្ញា ចាន់ កិត្យាភ៉ារ៉ា ចង់ក្លាយជាអ្នកវិភាគសេដ្ឋកិច្ច



ខ្ញុំពិតជាមានអារម្មណ៍រំភើបមែនទែន ដែលទទួលបានលទ្ធផលគួរជាទីមោទនៈបែបនេះ។ ហាក់ដូចជាក្តីសុបិន្តមួយដ៏មិនគួរឱ្យជឿសម្រាប់ខ្ញុំ។ នេះជាចំណាប់អារម្មណ៍របស់ កញ្ញា ចាន់ កិត្យាភ៉ារ៉ា សិស្សថ្នាក់ទី១២វិទ្យាល័យកំពង់ស្ពឺ។

ស្ថិតក្នុងវ័យ ១៧ ឆ្នាំកញ្ញា ចាន់ កិត្យាភ៉ារ៉ា ជាសិស្សឆ្នើមម្នាក់ដែលបានប្រឡងជាប់ចំណាត់ថ្នាក់និទ្ទេស A ក្នុងចំណោមបេក្ខជនជិត៩ម៉ឺននាក់នាសម័យប្រលងសញ្ញាបត្រទុតិយភូមិឆ្នាំនេះ(២០១៤) ជាសម័យប្រលងមានការរឹតបន្តឹង។ អ្វីដែលជាការកត់សំគាល់នោះ កិត្យាភ៉ារ៉ា បានធ្វើឱ្យគ្រប់មជ្ឈដ្ឋានសង្គមមានការកោតសសើរ និងគាំទ្រយ៉ាងខ្លាំងចំពោះលទ្ធផលដ៏ថៃ្ងថ្លានេះ។ ជាពិសេសសម្តេចតេជោបានផ្តល់នូវអាហារូបករណ៍រៀននៅគ្រប់សកលវិទ្យាល័យមួយក្នុងរាជធានីភ្នំពេញ ទៅតាមចំណង់ចំណូលចិត្តចង់រៀន។ មានកំណើតនៅភូមិសំណាង់ ឃុំរកាធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ កញ្ញា កិត្យាភ៉ារ៉ា មានបងប្អូនប្រុសស្រីបីនាក់ នាងជាកូនទី២។ ភ៉ារ៉ា មានឪពុកឈ្មោះ ចាន់ ភារៈ ជាមន្ត្រីបំរើការងារនៅមន្ទីរសង្គមកិច្ចខេត្ត ម្តាយឈ្មោះ ឡុង ហ៊ួយមាស

ជាមេផ្ទះ។ បច្ចុប្បន្ន កញ្ញា ចាន់ កិត្យាភ៉ារ៉ា កំពុងសិក្សានៅសកលវិទ្យាល័យអាមេរិកកាំងភ្នំពេញ ប៉ុន្តែមិនទាន់ជ្រើសរើសយកមុខជំនាញណាមួយពិតប្រាកដនោះទេ។ តែទោះជាយ៉ាងណាភ៉ារ៉ានិយាយថានាងមានគោលបំណងចាប់យកមុខជំនាញផ្នែកសេដ្ឋកិច្ច ព្រោះនាងស្រឡាញ់ផ្នែកនេះដោយចង់ប្រែក្លាយទៅជាអ្នកវិភាគសេដ្ឋកិច្ចមួយរូបរួមចំណែកជួយដល់សេដ្ឋកិច្ចប្រទេសជាតិឱ្យមានកំណើនលូតលាស់ដូចប្រទេសជិតខាង កញ្ញា កិត្យា ភ៉ារ៉ា អះអាងថានាងមានជំនឿចិត្តលើខ្លួនឯងពិតជាអាចធ្វើបាន ៕ ***ស្រីពេជ្រ***

## រាជធានីភ្នំពេញ



" ខ្ញុំរៀនជាប់លេខ១ ឬលេខ២ ជារៀងរាល់ឆ្នាំ " តាំងពីរៀននៅថ្នាក់មតេយ្យមក។ ខ្ញុំពិតជាមានមោទនៈភាពណាស់ចំពោះលទ្ធផលប្រឡងនេះក៏ដោយសារប៉ាម៉ាក់ជាអ្នកលើកទឹកចិត្ត និងជម្រុញខ្ញុំ ។ នេះជាចំណាប់អារម្មណ៍របស់កញ្ញា សម្បត្តិ វិបុលរ័ត្ន សិស្សថ្នាក់ទី១២ វិទ្យាល័យព្រះស៊ីសុវត្ថិ។

កញ្ញា សម្បត្តិ វិបុលរ័ត្ន មានវ័យ ១៨ ឆ្នាំ ជាសិស្សឆ្នើមដែលបានប្រឡងជាប់ចំណាត់ថ្នាក់និទ្ទេសA លេខរៀងទី៥ លំដាប់ពិន្ទុ ៩៩,៩៩៦ ក្នុងចំណោមបេក្ខជនទូទាំងប្រទេសនាសម័យប្រឡងសញ្ញាបត្រទុតិយភូមិឆ្នាំ ២០១៤។ កញ្ញាបានធ្វើឱ្យគ្រប់មជ្ឈដ្ឋានមានការកោតសសើរ និងគាំទ្រយ៉ាងខ្លាំងចំពោះលទ្ធផលប្រឡងនេះដោយទទួលបានអាហាររូបករណ៍រយៈពេល៨ឆ្នាំរហូតរៀនចប់បរិញ្ញាបត្រ ។ វិបុលរ័ត្ន ជាកូនច្បងក្នុងចំណោមបងប្អូនស្រី ២នាក់ មានស្រុកកំណើតនៅខេត្តបាត់ដំបង ប៉ុន្តែបានមករស់នៅទីក្រុងភ្នំពេញតាំងពីអាយុ ៨ឆ្នាំ (ឆ្នាំ២០០៩) ។ ឪពុកឈ្មោះ ហង្ស សម្បត្តិ ជានាយទាហាន ម្តាយឈ្មោះ សុង វិបុល ជាគ្រូពេទ្យបម្រើការងារនៅមន្ទីរពេទ្យព្រះអង្គឌួង ។ បច្ចុប្បន្ន វិបុលរ័ត្ន កំពុងសិក្សានៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (សាលាតិចណូ)។ នាងបាននិយាយថា មូលហេតុដែលរៀននៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដោយសារពូកែផ្នែកវិទ្យាសាស្ត្រ គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា ទើបនាងមានគោលបំណងចាប់យកមុខជំនាញផ្នែកគូរប្លង់ ព្រោះស្រឡាញ់ផ្នែកនេះតាំងពីតូច៕ ***សោភា***

## ខេត្តកំពង់ចាម

យុវសិស្ស អិត ស្រីពៅ អតីតសិស្សស្រីមួយរូបដែលទទួលបាននិទ្ទេស A នាសម័យប្រឡងមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៤ នេះ បច្ចុប្បន្នប្អូនស្រីកំពុងសិក្សាថ្នាក់មូលដ្ឋាននៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ដោយទទួលបានអាហាររូបករណ៍ពេញលេញរយៈពេល៨ឆ្នាំ។

# សិស្សឆ្នើមនិទ្ទេស A នាសម័យប្រឡងមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៤



កើតក្នុងត្រកូលកសិករដែលមានបងប្អូនប្រុសខនាក់ ប្អូនស្រី អិត ស្រីពៅ ជាកូនស្រីទោល (កូនទី៨) និងជាកូនដែលធ្វើឲ្យគ្រួសារក៏ដូចជាគ្រូបណ្ដុះបណ្ដាលនៅវិទ្យាល័យសម្ដេចជួនណាត ខេត្តកំពង់ចាម មានមោទនភាព ។ លោកស្រី ទឹម ឡាប ជាម្ដាយប្អូនស្រីបានឲ្យដឹងថា លោកស្រីមិនមានក្ដីស្រមៃថាកូនស្រីនឹងមានឱកាសចូលរៀនមហាវិទ្យាល័យឡើយ ដោយសារគ្រួសារគ្មានប្រាក់គ្រប់គ្រាន់ដើម្បីឧបត្ថម្ភការសិក្សាថ្នាក់ឧត្ដមសិក្សានេះ។ ដើម្បីមានជោគជ័យដូចថ្ងៃនេះប្អូនស្រីបាននិយាយថា ជាមធ្យមប្អូនស្រីចំណាយពេលលើសពី១០ម៉ោងក្នុងមួយថ្ងៃសម្រាប់ការសិក្សា ដូចជា ធ្វើលំហាត់ អានសៀវភៅ ដោយយកចិត្តទុកដាក់ និងការតាំងចិត្ត។

បើទោះបីជានឹងមានបញ្ហាប្រឈមនៅថ្នាក់មហាវិទ្យាល័យ ដោយសារចំណេះដឹងផ្នែកភាសាបរទេសនៅមានកម្រិត ប្អូនស្រីតាំងចិត្ត និងខិតខំរៀនឲ្យទទួលបានលទ្ធផលល្អ ដើម្បីយកចំណេះដឹងនេះរំដោះខ្លួនចេញពីភាពក្រីក្រ ដើម្បីជួយគ្រួសារ និងសង្គមជាតិ៕ ***បូរី***

## ខេត្តសៀមរាប



យុវសិស្ស អ៊ុត សុខផល្លុន ជាសិស្សនិទ្ទេស A មកពីខេត្តសៀមរាប ។ ដោយមានចិត្តស្រឡាញ់ផ្នែក វេជ្ជសាស្ត្រតាំងពីក្មេងមក ផល្លុនបានសម្រេចចិត្តជ្រើសយកមុខជំនាញនេះនៅមហាវិទ្យាល័យមួយក្នុងរាជធានីភ្នំពេញ ដោយទទួលបានអាហារូបករណ៍ពេញលេញ។

យុវសិស្ស សុខផល្លុន ដែលមានឪពុកជាមន្ត្រីប៉ូលីស និងម្ដាយជាអាជីវករ បានឲ្យដឹងថា នាងបានទទួលលទ្ធផលល្អក្នុងការសិក្សាតាំងពីថ្នាក់បឋមសិក្សាមក។ ក្នុងនោះកត្តាសំខាន់បីយ៉ាងដែលនាងជឿថា ធ្វើឲ្យនាងទទួលបានលទ្ធផលល្អក្នុងការសិក្សាគឺ ខ្លួនឯង មិត្តភ័ក្ត្រ និងគ្រូបណ្ដុះបណ្ដាល ។ ជាងនេះទៀតនាងតែងតែទទួលបានការលើកទឹកចិត្ត និងគាំទ្រពីគ្រួសារផងដែរ។ ផល្លុនបានឲ្យដឹងថា ទោះបីជាស្ថិតក្នុងយុវវ័យភាពក៏ដោយ ប៉ុន្តែរូបនាងបានចំណាយពេលវេលាតិចតួចបំផុតទៅលើការកំសាន្តពីព្រោះភាគច្រើនត្រូវចំណាយពេលលើការសិក្សា ដែលនាងរៀបចំជាតារាងកម្មវិធីសិក្សាខ្លួនឯង និងពេលសម្រាប់សិក្សាភាសាបរទេសទាំងភាសាបារាំង និងអង់គ្លេស។

មូលហេតុសំខាន់ដែលធ្វើឲ្យយុវសិស្សរូបនេះខិតខំរៀន ដោយសារនាងមានក្ដីស្រមៃចង់ប្រឡងជាប់ទទួលអាហារូបករណ៍ទៅបន្តការសិក្សានៅបរទេស និងយកចំណេះដឹងនេះដើម្បីប្រែក្លាយខ្លួនទៅជាបុគ្គលល្បីមួយរូបក្នុងសង្គម៕ ***បូរី***

# សិក្ខាសាលាថ្នាក់ជាតិ ស្តីពី ការអនុវត្តផែនការសកម្មភាព នៃសន្និសីទស្ត្រី នាទីក្រុងប៉េកាំងក្នុងរយៈពេល ២០ឆ្នាំ




សិក្ខាសាលានេះគឺជាការជួបជុំអ្នកពាក់ព័ន្ធសំខាន់ៗ ពីស្ថាប័នរដ្ឋ វិស័យឯកជន និងសង្គមស៊ីវិល ដើម្បីផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍ជាតិ ស្តីពីវឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាព នៃសន្និសីទស្ត្រីនាទីក្រុងប៉េកាំង កាលពីឆ្នាំ១៩៩៥ និងកំណត់រកចំណុចទិសដៅអាទិភាពក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីកម្ពុជា ។ ***វឌ្ឍនា***



## កិច្ចប្រជុំបណ្តាញយុវជនក្រសួងកិច្ចការនារី







លោកជំទាវវេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ជាអធិបតីក្នុងកិច្ចប្រជុំបណ្តាញយុវជន កាលពីពេលថ្មីៗនេះនៅទីស្តីការក្រសួងកិច្ចការនារី ដើម្បីពិភាក្សាលើតម្រូវការ តួនាទី និងភារៈទទួលខុសត្រូវរបស់យុវជន ក្នុងការចូលរួមអនុវត្តការងារជូនក្រសួងកិច្ចការនារី និងសង្គមជាតិ ។

# ណែនាំពីតួនាទីភារកិច្ចដល់គណៈកម្មការចម្រុះថ្នាក់ក្រោមជាតិ!




**លោកជំទាវ ហ៊ូ សាមិត្ត រដ្ឋលេខាធិការក្រសួងកិច្ចការនារី ជាគណៈអធិបតីក្នុងវគ្គបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលតួនាទីភារៈកិច្ចរយៈពេល ៣ថ្ងៃ ដល់មន្ត្រីគណៈកម្មការចម្រុះថ្នាក់ក្រោមជាតិ នៅសណ្ឋាគារតោមាសខេត្តព្រះសីហនុ បានរៀបចំដោយគណៈកម្មាធិការថ្នាក់ជាតិ លើកកម្ពស់សីលធមិសង្គមតម្លៃស្ត្រី និងគ្រួសារខ្មែរ (គ.ជ.ស.ស.ខ) កាលពីថ្ងៃទី ២៧-២៩ ខែឧសភា ឆ្នាំ២០១៤។

វគ្គសិក្សានេះ ប្រព្រឹត្តទៅក្រោមអធិបតីភាព លោកជំទាវ **ហ៊ូ សាមិត្ត** រដ្ឋលេខាធិការក្រសួងកិច្ចការនារី លោកជំទាវ **ចាន់ ធី** រដ្ឋលេខាធិការក្រសួងព័ត៌មាន លោកស្រី **ប្រាក់ ច័ន្ទសុខា** អភិ-



**លោកស្រី ប្រាក់ ច័ន្ទសុខា អភិបាលរង នៃគណៈអភិបាល ខេត្តព្រះសីហនុ មានមតិស្វាគមន៍ក្នុងអង្គពិធី**

បាលរង នៃគណៈអភិបាលខេត្តព្រះសីហនុ និងមានសិក្ខាកាមចូលរួមជាសមាជិក សមាជិកា គណៈកម្ម-ការចម្រុះថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ចំនួន៤ មានខេត្តកោះកុង កំពង់ស្ពឺ កំពង់ឆ្នាំង និងខេត្ត ព្រះសីហនុ ចំនួន៧៣នាក់ ក្នុងនោះស្ត្រី៥៦នាក់ សំដៅបង្កើនការយល់ដឹងអំពីរចនាសម្ព័ន្ធតួនាទី គ.ជ.ស.ស.ខ ថ្នាក់ជាតិ និងក្រោមជាតិ ដូចជាសីលធមិសង្គមតម្លៃស្ត្រី និងគ្រួសារខ្មែរ ក្នុងវិស័យព្រះពុទ្ធសាសនា វិស័យទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ ក្រមសីលធមិ វិស័យព័ត៌មាន និងតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយបច្ចេកទេសក្នុងការកាត់បន្ថយ និងផ្សព្វផ្សាយព័ត៌មានវិទ្យា ពាក់ព័ន្ធនឹងរូបភាពអាសអាភាស ក៏ដូចជាការលើកកម្ពស់ការយល់ដឹងអំពី អនុក្រឹត្យពាក់ព័ន្ធនឹងការលើកកម្ពស់សីលធមិសង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ៕ ***ស្រីពេជ្រ***

# សកម្មភាពទប់ស្កាត់អំពើហិង្សាលើស្ត្រី

## វគ្គបណ្ដុះបណ្ដាល ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ

កាលពីពេលថ្មីៗនេះ នាយកដ្ឋានការពារផ្លូវច្បាប់ នៃក្រសួងកិច្ចការនារី សហការជាមួយមន្ទីរកិច្ចការនារីខេត្តបន្ទាយមានជ័យ បានរៀបចំវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ធ្វើនៅសាលាគរុកោសល្យ ស្ថិតនៅភូមិទី៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ មានរយៈពេលចំនួន៤ថ្ងៃ ចាប់ពីថ្ងៃទី ២៣ ដល់ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៤ ដល់មន្ត្រីចំនួន៤០រូប មកពីខេត្តចំនួន៧ រួមមានៈ ខេត្តបន្ទាយមានជ័យ កំពង់ធំ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ ប៉ៃលិន ខេត្តពោធិសាត់ និងមន្ត្រីក្រសួងកិច្ចការនារី ក្នុងគោលបំណងផ្ដល់ចំណេះដឹងអំពីការទប់ស្កាត់អំពើហិង្សានៅក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ តាមរយៈផ្ទាំងរូបភាព ខ្សែវីដេអូរឿង ដល់គ្រូបង្គោលដើម្បីរួមគ្នាផ្សព្វផ្សាយបន្តទៅសហគមន៍៕ *សុខខេង*



លោកជំទាវ ស៊ី ដេហ្វីន រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី ជាអធិបតីក្នុងអង្គពិធី ខេត្តបន្ទាយមានជ័យ



លោកស្រី ព្រហ្ម សុបិន ប្រធានការិយាល័យទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារកំពុងធ្វើបទបង្ហាញ



គណៈអធិបតីថតរូបអនុស្សាវរីយ៍ជាមួយសិក្ខាកាម

# ឥទ្ធិពលនៃការផ្លាស់ប្តូរ



នាយកដ្ឋានការពារផ្លូវច្បាប់នៃក្រសួងកិច្ចការនារី (កកន) បានរៀបចំវគ្គបណ្តុះបណ្តាលថ្នាក់តំបន់រយៈពេល ៤ថ្ងៃ ដល់គ្រូបង្គោលក្នុងខេត្តកោះកុង កាលពីថ្ងៃទី ២៥ ដល់ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៤ តាមរយៈផ្ទាំងរូបភាព និងបញ្ចាំងខ្សែវិដេអូរឿង " ឥទ្ធិពល នៃការផ្លាស់ប្តូរ " ។

វគ្គសិក្សានេះប្រព្រឹត្តទៅក្រោមអធិបតីភាពលោកជំទាវ **ទេស ច័ន្ទសារឿន** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី លោកស្រី **អេង គីមនាង** អភិបាលរងនៃគណៈអភិបាលខេត្តកោះកុង លោកស្រី **ឈឹម សៀម** ប្រធានស្តីទីមន្ទីរកិច្ចការនារីខេត្តកោះកុង នឹងមានសិក្ខាកាមចូលរួមចំនួន៥០នាក់ ក្នុងនោះបុរស៦នាក់ សុទ្ធតែគ្រូបង្គោលមកពីមន្ទីរកិច្ចការនារីខេត្តចំនួន៨មាន ខេត្តព្រះសីហនុ កំពត កែប តាកែវ កណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង និងខេត្តកោះកុង ក្នុងគោលបំណងបង្កើនចំណេះដឹងពីវិធីសាស្ត្រទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះ ក៏ដូចជារបៀបប្រើប្រាស់ផ្ទាំងរូបភាព និងការបញ្ចាំងខ្សែវីដេអូ ផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានតាមតំបន់រៀងៗខ្លួន ដើម្បីឱ្យពួកគាត់យល់ដឹង និងចេះដោះស្រាយបញ្ហាក្នុងគ្រួសារដោយសន្តិវិធី រួមចំណែកទប់ស្កាត់កាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ។

អំពើហិង្សាក្នុងគ្រួសារជាការរំលោភបំពានផ្លូវកាយ ចិត្ត ភេទ និងផ្លូវសេដ្ឋកិច្ច ពីមនុស្សម្នាក់ទៅលើមនុស្សម្នាក់ទៀត។

គួររំលឹកថា ផ្សារភ្ជាប់ និងវគ្គបណ្តុះបណ្តាលនេះក៏មានការដឹកនាំសិក្ខាកាមចុះអនុវត្ត ការផ្សព្វផ្សាយផ្ទាល់នៅស្រុកបុទុមសាគរ ក្នុងឃុំពីរ មាន ឃុំអណ្តូងទឹក និងឃុំកណ្តាល ដោយមានប្រជាពលរដ្ឋចូលរួម ៤០០នាក់ ក្នុងនោះស្ត្រី ៣០០នាក់ ផងដែរ៕

***ស្រីពេជ្រ***



# វេទិកា យុវជន រួមគ្នាលប់បំបាត់អំពើហិង្សាលើស្ត្រី

នាយកដ្ឋានព័ត៌មាន នៃក្រសួងកិច្ចការនារី សហការជាមួយមន្ទីរកិច្ចការនារីខេត្ត និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង បានរៀបចំវេទិកា យុវជន រួមគ្នាលប់បំបាត់អំពើហិង្សាលើស្ត្រី កាលពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២១ ខែ វិច្ឆិកា ២០១៤ នៅខេត្តបាត់ដំបង។ អញ្ជើញចូលរួមជាអធិបតីមាន លោកជំទាវ **ឡុង សុផល្លី** អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ឯកឧត្តម **ប៊ុត គឹមសា** អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង និងលោកស្រី **ទិសុទ្ធ រដ្ឋា** អនុប្រធានមន្ទីរកិច្ចការនារីខេត្តបាត់ដំបង ក្នុងគោលបំណងដើម្បីបង្កើនការយល់ដឹងរបស់យុវវ័យ រួមគ្នាលប់បំបាត់អំពើហិង្សាលើស្ត្រី ដើម្បីឈានទៅរកគ្រួសារមួយមានសុភមង្គល។ វេទិកាយុវជននេះបានប្រព្រឹត្តទៅនៅវិទ្យាល័យក្តុលដូនទាវ វិទ្យាល័យហ្វាពន្លឺសិល្បៈ និងអនុវិទ្យាល័យវត្តគរ អ្នកចូលរួម មានមន្ទីរកិច្ចការនារីខេត្ត នាយកសាលា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស សរុបចំនួន ៤៥០ នាក់ ក្នុងនោះស្រី ២៤៨នាក់៕

*សោភា*




លោកជំទាវ **ឡុង សុផល្លី** អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ជាអធិបតីភាពក្នុងវេទិកានៅ វិទ្យាល័យក្តុលដូនទាវ ខេត្តបាត់ដំបង



សិស្សានុសិស្សក្នុងវេទិកានៅ អនុវិទ្យាល័យវត្តគរ



សិស្សលើកជាសំណួរទៅកាន់វាគ្មិនក្នុងវេទិកា នៅវិទ្យាល័យហ្វាពន្លឺសិល្បៈ



គណៈអធិបតីថតរូបអនុស្សាវរីយ៍ជាមួយសិស្សានុសិស្សនៅវិទ្យាល័យក្តុលដូនទាវ

# វគ្គបណ្តុះបណ្តាលទប់ស្កាត់អំពើជួញដូរមនុស្ស




**លោកជំទាវ សាន្ត អារុណា រដ្ឋលេខាធិការ ជាគណៈអធិបតីក្នុងវគ្គបណ្តុះបណ្តាល**

នាយកដ្ឋានការពារផ្លូវច្បាប់នៃក្រសួងកិច្ចការនារីបានរៀបចំវគ្គបណ្តុះបណ្តាលថ្នាក់តំបន់ស្តីពី សកម្មភាពទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានាដល់ជនបង្គោលនៅខេត្តស្ទឹងត្រែង កាលពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាពលោកជំទាវ **សាន្ត អារុណា** រដ្ឋលេខាធិការក្រសួងកិច្ចការនារី ឯកឧត្តម **ម៉ៅ ធនិន** អភិបាលរងនៃគណៈអភិបាលខេត្ត និងលោកស្រី **សន សុខា** ប្រធានមន្ទីរកិច្ចការនារីខេត្តស្ទឹងត្រែង។

វគ្គសិក្សានេះបានធ្វើនៅសណ្ឋាគារសេកុងស្តាររយៈពេល៣ថ្ងៃ ដោយមានសិក្ខាកាមចូលរួមសិក្សា ៤០នាក់ ក្នុងនោះស្រី ៣៩នាក់ ដែលសុទ្ធតែជាមន្ត្រីបង្គោល ទទួលបន្ទុកការងារកិច្ចការនារីនៅតាមភូមិ-ឃុំ-សង្កាត់-រាជធានី ខេត្ត/ក្រុង របស់ខេត្ត រតនៈគីរី, មណ្ឌលគីរី, ក្រចេះ, កំពង់ចាម, ព្រៃវែង, ស្វាយរៀង និងរាជធានីភ្នំពេញ។ គោលបំណងនៃវគ្គនេះគឺកសាងសមត្ថភាពដល់ជនបង្គោលទាំងនោះដើម្បីមានលទ្ធភាព អាចធ្វើសកម្មភាពថ្នាក់ភូមិទប់ស្កាត់ឈានទៅលុបបំបាត់ការធ្វើអាជីវកម្មមនុស្សឱ្យមានប្រសិទ្ធភាព ។




**លោកស្រី ស៊ុន វណ្ណា ឧទ្ទេសមេរៀន**

រយៈពេល ៣ ថ្ងៃ នៃការសិក្សា សិក្ខាកាមទាំងអស់បានខិតខំយកចិត្តទុកដាក់ទៅលើមេរៀនសំខាន់ៗចំនួន៧ សម្រាប់ជាស្ពានឈានទៅអនុវត្តសកម្មភាពផ្សព្វផ្សាយនៅក្នុងមូលដ្ឋានរួមចំណែកទប់ស្កាត់អំពើជួញដូរមនុស្ស រត់ពន្ធមនុស្ស ការធ្វើអាជីវកម្មមនុស្ស ក៏ដូចជាការធ្វើចំណាកស្រុកដោយប្រថុយប្រថាន៕ ***ស្រទម្ម***

# សកម្មភាពលើកកម្ពស់សុខភាពស្ត្រី



### កម្មវិធីប្រយុទ្ធ និងទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺកាមរោគ:

នាយកដ្ឋានស្ត្រី និងសុខភាព បានរៀបចំវេទិកាអប់រំ ស្តីអំពីជំងឺគ្រុនចាញ់បានចំនួន៩វេទិកា មានអ្នកចូលរួមជាមន្ត្រីថ្នាក់ជាតិអ្នកសម្របសម្រួលថ្នាក់ក្រោមជាតិ មណ្ឌលសុខភាព ភ្នាក់ងារ អប់រំសុខភាពភូមិ និងប្រជាពលរដ្ឋគោលដៅ សរុបចំនួន ៣៦១ នាក់ (ស្ត្រី ២៦៨នាក់) ស្ថិតក្នុងខេត្តចំនួន៩ គឺ សៀមរាប កំពង់ចាម បាត់ដំបង បន្ទាយមានជ័យ កំពត កំពង់ធំ កំពង់ស្ពឺ ពោធិ៍សាត់ និងកំពង់ឆ្នាំង គោលបំណងនៃវេទិកាគឺ បង្កើនការយល់ដឹងពីជម្ងឺគ្រុនចាញ់ដល់ក្រុមគោលដៅនៅតាមសហគមន៍ ។



### កម្មវិធីអាហារូបត្ថម្ភ:

នាយកដ្ឋានស្ត្រី និងសុខភាព បានរៀបចំបើកវគ្គបណ្តុះបណ្តាលដល់គ្រូបង្គោលស្តីពីអាហារូបត្ថម្ភរយៈពេល ៥ថ្ងៃ នៅសាលប្រជុំមន្ទីរកិច្ចការនារីខេត្តកំពង់ចាម ក្រោមកិច្ចសហការជាមួយអង្គការ TEMASEK POLYTECHNIC and TEMASEK FOUNDATION របស់ប្រទេសសិង្ហបុរី តាមរយៈការឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាលកម្ពុជា។ សិក្ខាកាមចូលរួមមានចំនួន ៥៨នាក់ (ស្ត្រី ៥២នាក់) ដែលជាមន្ត្រីកិច្ចការនារី ថ្នាក់ក្រសួង ថ្នាក់ខេត្ត និងការិយាល័យ កិច្ចការនារីស្រុក នៃខេត្តចំនួន ៨ គឺខេត្តកំពត កែប សៀមរាប ព្រះវិហារ កណ្តាល រាជធានីភ្នំពេញ ប៉ៃលិន និងខេត្តកោះកុង ។

# វេទិកា ស្តីពីបញ្ហាប្រឈមនៅក្នុងសង្គម និងផលប៉ះពាល់ដល់យុវវ័យ




**លោកជំទាវ អ៊ឹម ស៊ីថៃ រដ្ឋលេខាធិការ ជាគណៈអធិបតីក្នុងវេទិកា**

នាយកដ្ឋានស្រ្តី និងការអប់រំ នៃក្រសួងកិច្ចការនារី បានសហការជាមួយមន្ទីរកិច្ចការនារីខេត្តព្រះសីហនុ បានរៀបចំវេទិកាពិគ្រោះយោបល់ ក្រោមប្រធានបទ ស្តីពី បញ្ហាប្រឈមនៅក្នុងសង្គម និងផលប៉ះពាល់ ដល់យុវវ័យ កាលពីថ្ងៃទី១០ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ២០១៤ ក្នុងគោលបំណងដើម្បីបង្កើនការយល់ដឹង ពីសីលធម៌សង្គម និងកាត់បន្ថយរាល់ទស្សនៈ ឥរិយាបថអវិជ្ជមានរបស់យុវវ័យ។



**សិក្ខាកាមចូលរួមក្នុងវេទិកា**

វេទិកានេះរៀបចំនៅក្នុងស្រុកស្ទឹងហាវ និង ស្រុកព្រៃនប់និងក្នុងក្រុងព្រះសីហនុដោយមានអ្នក ចូលរួមចំនួន២៥០នាក់ ជាលោកគ្រូ អ្នកគ្រូ ប្រជា ពលរដ្ឋ សិស្សានុសិស្ស និងនិស្សិត ។

លោកជំទាវ **អ៊ឹម ស៊ីថៃ** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារីបានមានប្រសាសន៍ថា វេទិកា នេះពិតជាមានសារៈសំខាន់ណាស់ ដោយបាន ផ្តល់ឱកាសដល់យុវវ័យ បានបញ្ចេញមតិយោបល់ ពីបញ្ហាប្រឈម និងផលប៉ះពាល់ដល់យុវវ័យ។ លោកជំទាវ បានមានប្រសាសន៍ផ្តាំផ្ញើដល់យុវវ័យ យើងទាំងអស់គ្នាត្រូវចេះពិចារណា ពីព្រោះបច្ចុប្បន្ន បច្ចេកវិទ្យាព័ត៌មានជឿនលឿនណាស់ នឹងអាចធ្វើ ឲ្យប៉ះពាល់ដល់យុវវ័យយើង៕

***សុខខេង***

# ការខារដើម្បីពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី



សិក្ខាសាលាស្តីពីការអភិវឌ្ឍន៍ស្ត្រីក្នុងសហគ្រាស ដែលមានអ្នកចូលរួមជាថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងកិច្ចការនារី មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីខេត្តកំពង់ឆ្នាំង និងសៀមរាប តំណាងក្រសួងពាណិជ្ជកម្ម មន្ទីរឧស្សាហកម្មខេត្ត និងអាជីវករសមាគមអាជីវករ មានចំនួនសរុប ៧១នាក់ (បុរស ១៥នាក់) កាលពីថ្ងៃទី១២ ដល់ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅសណ្ឋាគារសោមាទេវីខេត្តសៀមរាប ក្នុងគោលបំណងដើម្បី៖ ១-ស្វែងយល់ពីបញ្ហាដែលស្ត្រីអាជីវករជួបប្រទះទាក់ទង នឹងការចុះបញ្ជី និងបង្កើនការយល់ដឹងជុំវិញការចុះបញ្ជីអាជីវកម្ម។ ២-បង្កើនការយល់ដឹងពីប្រតិបត្តិការអាជីវកម្មពាក់ព័ន្ធនឹងការនាំចេញ និងនាំចូលផលិតផល និងពិភាក្សាពីការលំបាកដែលអាជីវករជួបប្រទះ។ ៣-បង្កើនទំនាក់ទំនងរវាងស្ត្រីអាជីវករ ចែករំលែកបទពិសោធន៍ និងបញ្ហាផ្សេងៗទាក់ទងនឹងមុខរបរដែលស្ត្រី អាជីវករជួបប្រទះ៕





នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច នៃក្រសួងកិច្ចការនារី សហការជាមួយមន្ទីរកិច្ចការនារីខេត្តកំពង់ធំ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី " ការចាត់ចែងថវិកា " ដល់មន្ត្រីក្រសួងកិច្ចការនារី មន្ទីរកិច្ចការនារី និងមន្ត្រីមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ខេត្តកំពង់ធំ កំពង់ចាម កំពង់ឆ្នាំង កណ្តាល ព្រះវិហារ និងមន្ទីរកិច្ចការនារីរាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ដល់ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៤ ដែលមានអ្នកចូលរួមចំនួន៤២នាក់ ក្នុងនោះស្ត្រីចំនួន៤០នាក់ ក្នុងគោលបំណងដើម្បីបង្កើនសមត្ថភាពដល់មន្ត្រីមន្ទីរកិច្ចការនារី មន្ត្រីការិយាល័យកិច្ចការនារីស្រុក ក្រុង និងមន្ត្រីមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ក្នុងការអប់រំបន្តដល់សិស្ស និងស្ត្រីមូលដ្ឋាន អំពីជំនាញដែលទាក់ទងទៅនឹងការរកប្រាក់ចំណូល ការចំណាយ និងការវិនិយោគ ៕

# ការកសាងសមត្ថភាព

## មន្ត្រីថ្មី៨ខេត្ត ទទួលវគ្គបណ្តុះបណ្តាលការងារសវនកម្ម



**លោកជំទាវ ខេង សំវ៉ាដា រដ្ឋលេខាធិការ កកន ជាអធិបតីក្នុងវគ្គបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលស្តីពីការងារសវនកម្ម និងកិច្ចបញ្ជីការគណនេយ្យ ត្រូវបាននាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងកិច្ចការនារី រួមសហការជាមួយមន្ទីរកិច្ចការនារីខេត្តបន្ទាយមានជ័យ និងគាំទ្រដោយអាជ្ញាធរខេត្ត បានរៀបចំធ្វើឡើងរយៈពេល៤ថ្ងៃកាលពីថ្ងៃទី០៤-០៧ ខែកុម្ភៈ ឆ្នាំ២០១៤ ដើម្បីបង្កើនចំណេះដឹងដល់មន្ត្រីក្របខ័ណ្ឌថ្មីមកពីខេត្តចំនួន៨មាន ខេត្តសៀមរាប ឧត្តរមានជ័យ ព្រះវិហារ កំពង់ធំ ប៉ៃលិន បាត់ដំបង ពោធិសាត់ និងខេត្តបន្ទាយមានជ័យ សរុបសិក្ខាកាមចូលរួមសិក្សា ៤៥នាក់ ក្នុងនោះស្រី៣២នាក់។ វគ្គបណ្តុះបណ្តាលមានការចូលរួមផ្តល់អនុសាសន៍ពីសំណាក់លោកជំទាវ **ខេង សំវ៉ាដា** រដ្ឋលេខាធិការក្រសួងកិច្ចការនារី លោក **អ៊ី ឡុង** អភិបាលរងនៃគណៈអភិបាលខេត្ត និងលោកស្រី **អ៊ួង រស្មី** អនុប្រធានមន្ទីរកិច្ចការនារីខេត្តបន្ទាយមានជ័យ ក្នុងគោលបំណងកំណត់ និងធ្វើឱ្យមានលក្ខណៈជាគំរូនូវនីតិវិធីក្នុងការអនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុ ការងារសវនកម្ម និងការងារគ្រប់គ្រងហានិភ័យ ដើម្បីពង្រឹង និងកសាងសមត្ថភាពសវនករឱ្យបានដល់កម្រិតវិជ្ជាជីវៈគំរូណាមួយពិសេសធ្វើឱ្យប្រសើរឡើងនូវផលិតភាព និងកិច្ចសហប្រតិបត្តិការរបស់ក្រសួង និងមន្ទីរកិច្ចការនារីដើម្បីសម្រេចបានគោលដៅរួមប្រសិទ្ធភាព និងប្រសិទ្ធផល នៃកិច្ចសហប្រតិបត្តិការ។ ***ស្រីពេជ្រ***



គណៈអធិបតីថតរូបអនុស្សាវរីយ៍ជាមួយសិក្ខាកាម

# គម្រោងផែនការថវិកា ឆ្លើយតបនឹងយេនឌ័រ



លោកជំទាវ ច័ន្ទ សុរិយ៍ រដ្ឋលេខាធិការ កកន ជាអធិបតី ក្នុងអង្គពិធី នៅខេត្តកំពង់ធំ

សិក្ខាកាម៣០នាក់មកពីមន្ទីរកិច្ចការនារីខេត្ត ចំនួន៦ មាន ខេត្តក្រចេះ មណ្ឌលគិរី ស្ទឹងត្រែង កំពង់ចាម និងកំពង់ធំបានទទួលការបំប៉នសមត្ថភាព ពីរបៀបធ្វើគម្រោងផែនការថវិកាឆ្លើយតបយេនឌ័រ ដែលរៀបចំដោយនាយកដ្ឋានផែនការស្ថិតិក្រសួង កិច្ចការនារី កាលពីថ្ងៃទី ២៤ ដល់ថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៤។

វគ្គហ្វឹកហ្វឺននេះដំណើរការនៅក្នុងមន្ទីរ វប្បធម៌ខេត្តកំពង់ធំ ដោយមានការចូលរួមពី លោកជំទាវ **ច័ន្ទ សុរិយ៍** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ឯកឧត្តម **សឿ ម៉ុនហ៊ារ** អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ នៃក្រសួងកិច្ចការនារី លោកស្រី **យស ថានារី** អភិបាលរងនៃគណៈអភិបាល ខេត្តកំពង់ធំ និងលោកស្រី **ទូច ស៊ីថុល** ប្រធាន មន្ទីរកិច្ចការនារី ខេត្តកំពង់ធំ លោកស្រី **អ៊ុក ណានី** អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ (កកន) ក្នុងគោលបំណងបង្កើនសមត្ថភាព យល់ដឹងពី ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្លើយ តបនឹងយេនឌ័រនៅក្នុងការរៀបចំផែនការកម្មវិធី។



លោកស្រី អ៊ុក ណានី ឧទ្ទេសនាមមេរៀន

លោកជំទាវ **ច័ន្ទ សុរិយ៍** មានប្រសាសន៍ ទទួលស្គាល់ថារយៈពេល៥ថ្ងៃនៃការសិក្សាគឺពិត ជាមិនអាចទទួលបាននូវចំណេះដឹងទាំងអស់ទេ តែនេះជាបទពិសោធន៍សម្រាប់ជាមូលដ្ឋានគ្រឹះ សំខាន់ៗដើម្បីអាចឈានទៅអនុវត្តលើការរៀបចំ ផែនការសកម្មភាពឱ្យល្អ៕

*ស្រីពេជ្រ*

# វគ្គបណ្តុះបណ្តាល ស្តីពី ការបញ្ជ្រាបយេនឌ័រ ក្នុងការរៀបចំផែនការគម្រោងកម្មវិធីតាមវិធីសាស្ត្រ




**លោកជំទាវ ច័ន្ទ សូរីយ៉ រដ្ឋលេខាធិការ កកន ជាអធិបតី ក្នុងអង្គពិធី នៅខេត្តព្រះវិហារ**

កាលពីថ្ងៃទី២៧ ដល់ថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៤ នាយកដ្ឋានផែនការ និងស្ថិតិ ក្រសួងកិច្ចការនារី សហការជាមួយមន្ទីរកិច្ចការនារីខេត្តព្រះវិហារបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការបញ្ជ្រាបយេនឌ័រ ក្នុងការរៀបចំផែនការគម្រោងកម្មវិធីតាមវិធីសាស្ត្រ " ការគ្រប់គ្រងវដ្តនៃគម្រោងឆ្លើយតបនឹងយេនឌ័រ " ក្នុងគោលបំណងពង្រឹងសមត្ថភាពបន្ថែមដល់មន្ត្រីថ្នាក់ក្រោមជាតិឲ្យទទួលបាននូវជំនាញក្នុងការបញ្ជ្រាបយេនឌ័រក្នុងដំណើរការរៀបចំផែនការគម្រោង/កម្មវិធី ដើម្បីដាក់បញ្ចូលក្នុងទម្រង់នៃគោលការណែនាំ " ការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងថវិកាតាមកម្មវិធី " មកពីមន្ទីរកិច្ចការនារីខេត្តចំនួន៦ រួមមាន ខេត្តព្រៃវែង ស្វាយរៀង កំពង់ឆ្នាំង កណ្តាល រាជធានីភ្នំពេញ និងព្រះវិហារ សរុបចំនួន ៤០នាក់ ក្នុងនោះស្រី ៣២នាក់៕ *សោភា*







សិក្ខាកាមពិភាក្សាក្រុម




គណៈអធិបតីថតរូបអនុស្សាវរីយ៍ជាមួយសិក្ខាកាម

# វគ្គបណ្តុះបណ្តាលស្វែងរកការគាំទ្រមតិ

មន្ត្រីទទួលបន្ទុកការងារយេនឌ័រថ្នាក់ក្រោមជាតិ នៃមន្ទីរកិច្ចការនារីបានទៅជួបជុំគ្នានៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកែប ជាទីបណ្តុះបណ្តាលបន្ថែមពីវិធីសាស្ត្រស្វែងរកការគាំទ្រមតិ កាលពីថ្ងៃទី៤ ដល់ថ្ងៃទី ៨ ខែសីហា ឆ្នាំ២០១៤ ។

វគ្គហ្វឹកហ្វឺនដែលមានរយៈពេលបីថ្ងៃនេះរៀបចំដោយនាយដ្ឋានសមភាពយេនឌ័រ នៃក្រសួងកិច្ចការនារី ដោយមានការចូលរួមពី លោកជំទាវ **យ៉យ នីតា** អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី លោកស្រី **ខិន សុខខីម** សមាជិកក្រុមប្រឹក្សាខេត្ត និងលោកស្រី **កៅ នី** អនុប្រធានមន្ទីរកិច្ចការនារីខេត្តកែប។ វគ្គសិក្សានេះមានសិក្ខាមចូលរួម ៥០នាក់ ក្នុងនោះបុរស ៨នាក់មកពីខេត្តចំនួន ៦មាន ខេត្តកោះកុង ព្រះសីហនុ កំពត តាកែវ កំពង់ស្ពឺ និងខេត្តកែបម្ចាស់ផ្ទះ។ ការស្វែងរកការគាំទ្រមតិ គឺជាការបញ្ចុះបញ្ចូល និងជម្រុញការទាក់ទាញរបស់ថ្នាក់ដឹកនាំដើម្បីឈានទៅធ្វើសេចក្តីសម្រេចចិត្តរកដំណោះស្រាយ ជាពិសេសធ្វើយ៉ាងណាឱ្យអ្នកមានឥទ្ធិពល ឬធ្វើសេចក្តីសម្រេចទាំងនោះមានការចាប់អារម្មណ៍ ហើយទទួលយកនូវបញ្ហាទាំងនោះដាក់បញ្ចូលក្នុងគម្រោងអភិវឌ្ឍនានា៕



**លោកជំទាវ យ៉យ នីតា អនុរដ្ឋលេខាធិការ ក.ក.ន ជាអធិបតីក្នុងអង្គពិធី នៅខេត្តកែប**

*ស្រីពេជ្រ*



# ផ្តល់ភាពអង់អាចដល់ស្ត្រី និងក្មេងស្រីពិការ



លោកជំទាវ **ញ៉ែម មរកត** អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ជាអធិបតីក្នុងអង្គពិធី



សិក្ខាកាមចូលរួម (យុវវ័យពិការ)

អង្គការសកម្មភាពលើយុវវ័យពិការដើម្បីអភិវឌ្ឍន៍ សហការជាមួយក្រសួងកិច្ចការនារី បានបើកសិក្ខាសាលា ស្តីពី ផ្តល់ភាពអង់អាចដល់ស្ត្រី និងក្មេងស្រីពិការ ដើម្បីចូលរួមក្នុងសង្គមនៅអតីតមណ្ឌលកុលាប១ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០១៤ ក្នុងគោលបំណងផ្សព្វផ្សាយពីសិទ្ធិ និងស្ថានភាពស្ត្រីពិការ ដើម្បីផ្តល់ឱកាសសម្រាប់ស្ត្រីពិការក្នុងការបង្ហាញពីតម្រូវការ និងឧបសគ្គរបស់ពួកគាត់ ដើម្បីចូលរួមអភិវឌ្ឍន៍សង្គម ដែលមានអ្នកចូលរួមចំនួន ៩៣នាក់ (ស្រី ៧២នាក់) ។ គួរបញ្ជាក់ថា សិក្ខាសាលានេះក៏បានចែករំលែកបទពិសោធន៍ពីភាពជោគជ័យរបស់ស្ត្រីពិការ៕

*សុខខេង*



លោកជំទាវ ញ៉ែម មរកត អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ថតរូបអនុស្សាវរីយ៍ជាមួយសិក្ខាកាម

# ជីវិតស្ត្រីលក់ក្តាម

ខេត្តកែប គឺជាតំបន់ទេសចរណ៍ នៃប្រទេសកម្ពុជា ដែលបានជាប់ចំណាត់ថ្នាក់ជាឆ្នេរសមុទ្រដ៏ស្រស់ស្អាត ក្នុងចំណោមឆ្នេរនៃពិភពលោក។ ប្រសិនបើយើងទៅកំសាន្តនៅខេត្តកែប មានមនុស្សម្នាភាគច្រើនបានដឹងថាខេត្តនេះសម្បូរទៅដោយមច្ឆាជាតិជាច្រើនប្រភេទ មានត្រី មឹក បង្គា ពិសេសក្តាមដែលមានរសជាតិផ្អែមឆ្ងាញ់ពិសារ។ ដូច្នេះយើងក៏មិនភ្លេចអ្នកលក់ក្តាមដែរ?







អ្នករកស៊ីទិញ-លក់ក្តាមនៅខេត្តកែប

អ៊ំស្រី ម៉ៅ អាយុ៥១ឆ្នាំ ដែលមានទឹកមុខញញឹមរាក់ទាក់ ជាអ្នកលក់ក្តាមបានមានប្រសាសន៍ថា ដំបូងគាត់ជាអ្នកទទួលស្មោរក្តាមឱ្យគេប៉ុណ្ណោះ។ លុះក្រោយមកដោយការសន្សំប្រាក់បានខ្លះៗ ទើបអ៊ំស្រីបានទទួលក្តាមគេមកលក់ ហើយក្នុងមួយថ្ងៃៗ គឺគាត់អាចរកប្រាក់ចំណូលបានពី៣០.០០០៛ ទៅ ៤០.០០០៛។ អ៊ំស្រីបានមានប្រសាសន៍បន្តទៀតថា ជីវិតត្រូវតែតស៊ូ ថ្វីត្បិតខ្ញុំជាស្ត្រីមេម៉ាយ តែខ្ញុំមិនអស់សង្ឃឹមទេ ទោះបីខ្ញុំមានជម្ងឺប្រចាំកាយ និងជួបបញ្ហាជីវភាពអស់រយៈពេលជាង១០ឆ្នាំកន្លងមក នៅពេលប្តីរបស់ខ្ញុំបានទៅយកប្រពន្ធថ្មី ។ អ៊ំស្រីបានបន្ថែមថា ខ្ញុំបានតស៊ូ និងខិតខំចិញ្ចឹមបីបាច់ថែរក្សាកូនទាំងបីនាក់ តែកូនៗរបស់ខ្ញុំពួកគេបានរៀនត្រឹមតែថ្នាក់ទី៣ ប៉ុណ្ណោះ ពីព្រោះកូនៗត្រូវមកជួយលក់ក្តាមជាមួយខ្ញុំ។ អ៊ំស្រីម៉ៅ បានរៀបរាប់ដោយទឹកមុខញញឹមថា ខ្ញុំមិនប្តូរមុខរបរលក់ក្តាមនេះទេ ទោះបីគាត់មានអាយុច្រើនក៏ដោយ ព្រោះមុខរបរនេះអាចឲ្យគាត់សន្សំប្រាក់បានខ្លះៗ៕ ***បុណ្យរន្នីមល្លិកា***

# ការតស៊ូនាំមកនូវភាពជោគជ័យ



ក្នុងវ័យ ៦៧ឆ្នាំ លោកស្រី **យូន សារុម** គឺជាចៅសង្កាត់លេខ៤ ខេត្តព្រះសីហនុ។ លោកស្រីបានចូលបំរើការងារចាប់ពីឆ្នាំ១៩៧៩ ដំបូងគាត់ជាប្រធាននារីភូមិ ។ ដោយសារមានឆន្ទៈសកម្មការងារ លោកស្រីបានឡើងឋានៈតួនាទីជាបន្តបន្ទាប់ ជាពិសេសទៀតនោះលោកស្រីបានជាប់ជាចៅសង្កាត់លេខ៤ ក្នុងខេត្តព្រះសីហនុ ចាប់តាំងពីឆ្នាំ ២០០២ រហូតដល់បច្ចុប្បន្ន ។

ស្ថិតក្នុងទឹកមុខញញឹមរួសរាយរាក់ទាក់ លោកស្រី **យូន សារុម** បានឱ្យដឹងថា ការទទួលបានជោគជ័យលើវិថីការងាររហូតដល់សព្វថ្ងៃនេះ អាស្រ័យមានការគាំទ្រពីក្រុមគ្រួសារ ក្រុមការងារក្នុងសង្កាត់ និងប្រជាពលរដ្ឋនៅក្នុងសហគមន៍។ លោកស្រីបន្តទៀតថា ក្នុងនាមស្ត្រីថ្នាក់ដឹកនាំជាចៅសង្កាត់ ដំបូងជួបការលំបាកខ្លះៗព្រោះជាការងារថ្មី ។ ទោះជាជួបឧបសគ្គបន្តិចបន្តួចក្តី លោកស្រីនៅតែខិតខំបំរើការងារមិនគិតការនឿយហត់។ លោកស្រីសំណូមពរសូមរាជរដ្ឋាភិបាលបង្កើនចំនួនស្ត្រីជាថ្នាក់ដឹកនាំនៅមូលដ្ឋានឱ្យបានច្រើន ជាក់ស្តែងបច្ចុប្បន្នក្នុងខេត្តព្រះសីហនុមាន២៧ឃុំ/សង្កាត់ ក្នុងនោះស្ត្រីមានតែ១នាក់ជាចៅសង្កាត់ កត្តានេះជាឧបសគ្គក្នុងការស្វែងរកការគាំទ្រផលប្រយោជន៍សម្រាប់ស្ត្រី និងកុមារក្នុងមូលដ្ឋាន។

បងស្រី **សែម ហ៊ីម** ជាប្រជាពលរដ្ឋរស់នៅក្នុងសង្កាត់លេខ៤ ខេត្តព្រះសីហនុ គាត់មានមុខរបរលក់ដូរនៅមុខផ្ទះ បានប្រាប់អ្នកយកព័ត៌មានយើងថា លោកស្រី **យូន សារុម** ជាចៅសង្កាត់ដ៏ល្អដែលប្រជាជនស្រលាញ់និងពេញចិត្ត គាត់បានជាប់ជាចៅសង្កាត់រយៈពេល១២ឆ្នាំហើយ ។ បងស្រីបន្តទៀតថា លោកស្រី **យូន សារុម** ជួយប្រជាពលរដ្ឋនៅមូលដ្ឋានដោយមិនប្រកាន់ពូជសាសន៍ និងនិន្នាការនយោបាយឡើយ។ មិនតែប៉ុណ្ណោះគាត់តែងតែចុះសួរសុខទុក្ខប្រជាពលរដ្ឋពេលជួបការលំបាកដូចជា ជួសជុលផ្លូវលំ ជួយចាស់ជរាគ្មានទីពឹង ជួយដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារ និងជួយផ្សព្វផ្សាយអប់រំបញ្ហាសុខភាពជូនប្រជាពលរដ្ឋទូទៅជាពិសេសស្ត្រីមានផ្ទៃពោះអោយទៅពិនិត្យសុខភាពអោយបានទៀងទាត់៕ ***សារ៉ាត់***

## គួរយល់ដឹង

# មានជំងឺរលាកក្រពះ អ្នកត្រូវធ្វើអ្វីខ្លះ?



ជំងឺរលាកក្រពះអាចកើតមានឡើងភ្លាមៗ ឬអាចមានការវិវត្តបន្តិចម្តងៗនៅក្នុងករណីមួយចំនួន ។ ជំងឺរលាកក្រពះអាចនាំឱ្យមានដំបៅ និងការកើនឡើងនូវហានិភ័យនៃជំងឺមហារីកក្រពះ។ សម្រាប់មនុស្សភាគច្រើន ទោះជាយ៉ាងណាជំងឺរលាកក្រពះគឺ មិនធ្ងន់ធ្ងរឡើយ និងអាចធ្វើឱ្យវាបានប្រសើរឡើងយ៉ាងឆាប់រហ័សជាមួយនឹងការព្យាបាល។ អ្នកអាចនឹងបានធូរស្បើយពីរោគសញ្ញា ប្រសិនបើអ្នកបរិភោគអាហារតិចៗ តែញឹកញាប់ ប្រសិនបើអ្នកជួបប្រទះការមិនរំលាយអាហារជាញឹកញាប់ សូមបរិភោគអាហារតិចៗ តែញឹកញាប់ ដើម្បីជួយសម្រួលដល់ឥទ្ធិពលនៃអាស៊ីតក្រពះក្នុងការរំលាយអាហារ។

* ជៀសវាងអាហារមួយចំនួនៈ ជៀសវាងអាហារទាំងឡាយណាដែលអាចធ្វើឱ្យរលាកក្រពះរបស់អ្នក ជាពិសេសអាហារដែលហឹរ អាហារមានជាតិអាស៊ីត អាហារចៀន ឬអាហារ ខ្លាញ់។

* ញ៉ាំគ្រឿងស្រវឹងក្នុងកម្រិតមធ្យមៈ ការប្រើប្រាស់គ្រឿងស្រវឹងច្រើនហួសហេតុអាចធ្វើឱ្យរលាកស្រទាប់ក្នុងនៃក្រពះរបស់អ្នក។

* សូមពិចារណាលើការប្តូរថ្នាំបំបាត់ការឈឺចាប់ ៖ ប្រសិនបើអ្នកកំពុងប្រើថ្នាំបំបាត់ការឈឺចាប់ជាទៀងទាត់ សូមសួរគ្រូពេទ្យពីថ្នាំ Acetaminophen ( Tylenol ឬ ថ្នាំផ្សេងទៀត) ដែលអាចជាជម្រើសមួយសម្រាប់អ្នក។ ថ្នាំទាំងនេះ គឺមិននាំឱ្យមានបញ្ហាក្រពះធ្ងន់ធ្ងរនោះឡើយ។

* គ្រប់គ្រងភាពតានតឹងៈ ភាពតានតឹងអាចធ្វើឱ្យរោគសញ្ញារលាកក្រពះរបស់អ្នកកាន់តែអាក្រក់ឡើង ។ ភាពតានតឹងអាចជារឿងចៀសមិនផុត ប៉ុន្តែអ្នកអាចរៀនដោះស្រាយជាមួយនឹងវា។ ប្រសិនបើអ្នកមានបញ្ហានេះ ចូរពិចារណាលើការសម្រួលអារម្មណ៍មួយចំនួន ដូចជាការសមាធិ ការហាត់យូហ្គា ឬក្បាច់ថៃជិចិន ជាដើម៕

ដកស្រង់ពី Everyday News ដោយសោភា



# ក្រុមស្ត្រីសហគមន៍ផលិតកន្ត្រកល្ពាក់

# ក្នុងស្រុកព្រះស្ដេច ខេត្តព្រៃវែង